**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No. 10 PR-24/EoJ 19 February 2025

## Japan Provides US$462,003 for Procurement of Japanese Fire Trucks and Installation of Medical Equipment

The Government of Japan will provide US$462,003 in total for two recipient organizations under the framework, *the Grant Assistance for Grassroots Human Security Projects ("KUSANONE")*. The Grant Contracts were signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of the two recipients, to carry out the following projects.

1. 'The Project for Procurement of Japanese Smoke Ventilation Truck in Phnom Penh' (US$83,672)
Recipient: Phnom Penh Capital Administration
In this project, a smoke ventilation truck, which will be the first fire engine of this kind ever used in Cambodia, will be deployed in Phnom Penh in order to improve firefighting capability. This will help firefighters respond to fires including huge and large cases more quickly and efficiently by implementing smoke ventilation from buildings at fire incident. This contribute to the protection for over 2.8 million people's lives and possessions in Phnom Penh from fire incidents. The vehicle was provided by Fire and Disaster Management Agency (FDMA), Ministry of Internal Affairs and Communications of Japan.

2. 'The Project for the Procurement of Secondhand Fire Truck and Rescue Truck in Phnom Penh' (US$154,376)
Recipient: Phnom Penh Capital Administration
In this project, a rescue truck, which will be the first kind of truck ever used in Phnom Penh and a ladder truck with a 40-meter ladder will be deployed in Phnom Penh in order to improve rescue and firefighting capability. A rescue truck enables firefighters to respond to accidents including specific situations save that make rescue activities difficult. A ladder truck will help firefighters to improve the firefighting capacity to cope with variety of cases including at high building. This improves safety for, and helps protect the properties of approximately 2.8 million residents of Phnom Penh, as well as tourists and business travelers from around the world.

3. ‘The Project for the Installation of Medical Equipment at Preah Ang Duong Hospital in Phnom Penh’ (US$223,955)
Recipient: Preah Ang Duong Hospital
This grant will be used to procure 3 kinds of medical equipment for ear, nose, and throat (ENT) surgery (3 forceps, 1 set of drill and shaver, 1 set of endoscope camera and monitor) to improve the quality of ENT surgery at Preah Ang Duong Hospital. It would enhance the efficiency and productivity of medical doctors and nurses who take care of patients in this hospital. Through the improved medical services, it is expected to benefit around 32,000 patients including 1,400 low income patients.

Japan’s *“KUSANONE” Projects* started in Cambodia in 1991 in order to support Cambodia’s reconstruction and development at the grassroots level. The assistance aims to protect those who are vulnerable due to various factors such as poverty and/or misfortunes that directly threaten their lives, livelihood, and dignity, as well as to promote self-reliance of local communities. Since 1991, the Government of Japan has provided over US$71 million for mainly local authorities and non-governmental organizations to implement 700 *KUSANONE* projects throughout Cambodia.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161, fax: 023-214-330*
*Email:* eco.jpn@pp.mofa.go.jp
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
# សេចក្តីប្រកាសព័ត៌មាន

លេខ. 10 PR-24/EoJ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៥

## ជប៉ុនផ្តល់ថវិកា ៤៦២,០០៣ ដុល្លារអាមេរិក សម្រាប់លទ្ធកម្មរថយន្តពន្លត់អគ្គិភ័យជប៉ុន និងការបំពាក់បរិក្ខារពេទ្យ

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន **៤៦២,០០៣ ដុល្លារអាមេរិក** ដល់ស្ថាប័នទទួលជំនួយចំនួនពីរ ក្រោមគ្រោងការណ៍ ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (គូសាណូណិ)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំ ព្រះរាជាណាចក្រកម្ពុជា និងតំណាងស្ថាប័នទទួលជំនួយទាំងពីរ ដើម្បីអនុវត្តគម្រោងខាងក្រោម៖

**១. "គម្រោងធ្វើលទ្ធកម្មរថយន្តបាញ់ខ្យល់របស់ជប៉ុន ក្នុងរាជធានីភ្នំពេញ" (ថវិកាចំនួន ៨៣,៦៧២ ដុល្លារអាមេរិក)**
ស្ថាប័នទទួលជំនួយ៖ រដ្ឋបាលរាជធានីភ្នំពេញ

ក្នុងគម្រោងនេះ រថយន្តបាញ់ខ្យល់ចំនួនមួយ ដែលនឹងក្លាយជាម៉ាស៊ីនពន្លត់អគ្គិភ័យប្រភេទបាញ់ខ្យល់ដំបូងគេបង្អស់ដែលដាក់ឲ្យប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ដែលនឹងត្រូវបានដាក់ពង្រាយក្នុងរាជធានីភ្នំពេញ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពពន្លត់អគ្គិភ័យ។ រថយន្តនេះនឹងជួយឱ្យក្រុមពន្លត់អគ្គិភ័យឆ្លើយតបទៅនឹងស្ថានភាពអគ្គិភ័យនានា ដែលរួមទាំងករណីអគ្គិភ័យធំៗ កាន់តែរហ័សនិងមានប្រសិទ្ធភាព ដោយការអនុវត្តការបាញ់ខ្យល់ចេញពីអាគារមានឧប្បត្តិហេតុអគ្គិភ័យ។ រថយន្តនេះរួមចំណែកដល់ការការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាជនជាង ២,៨លាននាក់ ក្នុងរាជធានីភ្នំពេញពីឧប្បត្តិហេតុអគ្គិភ័យ។ រថយន្តនេះត្រូវបានផ្តល់ជូនដោយទីភ្នាក់ងារគ្រប់គ្រងអគ្គិភ័យ និងគ្រោះមហន្តរាយ នៃក្រសួងកិច្ចការផ្ទៃក្នុង និងទូរគមនាគមន៍ជប៉ុន។

**២. "គម្រោងធ្វើលទ្ធកម្មរថយន្តពន្លត់អគ្គិភ័យ និងរថយន្តសង្គ្រោះបន្ទាន់ដែលប្រើប្រាស់រួច ក្នុងរាជធានីភ្នំពេញ" (ថវិកាចំនួន ១៥៤,៣៧៦ ដុល្លារអាមេរិក)**
ស្ថាប័នទទួលជំនួយ៖ រដ្ឋបាលរាជធានីភ្នំពេញ

ក្នុងគម្រោងនេះ រថយន្តសង្គ្រោះបន្ទាន់ចំនួនមួយ ដែលនឹងក្លាយជារថយន្តសង្គ្រោះអគ្គិភ័យ

ដំបូងគេបង្អស់ដែលដាក់ឲ្យប្រើប្រាស់នៅក្នុងរាជធានីភ្នំពេញ រួមជាមួយរថយន្តពន្លត់អគ្គិភ័យជណ្តើរយន្តដែលបំពាក់ដោយកាំជណ្តើរកម្ពស់៤០ម៉ែត្រចំនួនមួយ នឹងត្រូវបានដាក់ពង្រាយក្នុងរាជធានីភ្នំពេញ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពសង្គ្រោះបន្ទាន់និងពន្លត់អគ្គិភ័យ។ រថយន្តសង្គ្រោះបន្ទាន់អាចឱ្យក្រុមពន្លត់អគ្គិភ័យឆ្លើយតបទៅនឹងស្ថានភាពជាក់លាក់នានា រួមទាំងគ្រោះថ្នាក់ផ្សេងៗ ដែលធ្វើឱ្យការជួយសង្គ្រោះមានភាពលំបាក។ រថយន្តពន្លត់អគ្គិភ័យជណ្តើរយន្តនឹងជួយក្រុមពន្លត់អគ្គិភ័យក្នុងការពង្រឹងសមត្ថភាពពន្លត់អគ្គិភ័យ ដើម្បីទប់ទល់នឹងករណីផ្សេងៗ ដូចជានៅអាគារខ្ពស់ៗជាដើម។ គម្រោងនេះធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពសម្រាប់ប្រជាជន និងជួយការពារទ្រព្យសម្បត្តិរបស់ប្រជាជនប្រមាណ ២,៨លាននាក់ ក្នុងរាជធានីភ្នំពេញ ក៏ដូចជាសម្រាប់ភ្ញៀវទេសចរ និងពាណិជ្ជករអន្តរជាតិដែលមកពីជុំវិញពិភពលោក។

**<u>៣. "គម្រោងបំពាក់បរិក្ខារពេទ្យនៅមន្ទីរពេទ្យព្រះអង្គឌួង ក្នុងរាជធានីភ្នំពេញ" (ថវិកាចំនួន ២២៣,៩៥៥ ដុល្លារអាមេរិក)</u>**

<u>ស្ថាប័នទទួលជំនួយ៖ មន្ទីរពេទ្យព្រះអង្គឌួង</u>

ជំនួយនេះនឹងត្រូវប្រើប្រាស់សម្រាប់ធ្វើលទ្ធកម្មសម្ភារៈបរិក្ខារពេទ្យចំនួន ៣ប្រភេទ សម្រាប់ការវះកាត់ផ្នែកត្រចៀក ច្រមុះ បំពងក (ហ្វកសិប៣ឈុត ម៉ាស៊ីនជ្រៀលនិងម៉ាស៊ីនសេវេី១ឈុត ម៉ាស៊ីនវះអង់ដូស្កូប១ឈុត) ដើម្បីពង្រឹងគុណភាពនៃការវះកាត់ផ្នែកត្រចៀក ច្រមុះ បំពងក នៅមន្ទីរពេទ្យព្រះអង្គឌួង។ គម្រោងនេះនឹងលើកកម្ពស់ប្រសិទ្ធភាព និងផលិតភាពរបស់វេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកា ដែលមើលថែទាំអ្នកជំងឺនៅក្នុងមន្ទីរពេទ្យនេះ។ តាមរយៈការពង្រឹងសេវាវេជ្ជសាស្ត្រ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់អ្នកជំងឺប្រមាណ ៣២,០០០នាក់ ដែលរួមទាំងអ្នកជំងឺមានប្រាក់ចំណូលទាបចំនួន ១,៤០០នាក់។

ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញ នៅកម្រិតមូលដ្ឋាន។ ជំនួយឥតសំណងនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង/ឬ ភាពអកុសលនានា ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់អាយុជីវិត ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកា ជាង៧១លានដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន ៧០០គម្រោង នៅទូទាំងប្រទេសកម្ពុជា៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីម៉ែល៖* eco.jpn@pp.mofa.go.jp
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

**សុន្ទរកថារបស់ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**
**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង**
**សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ**
**ថ្ងៃ១៩ ខែកុម្ភៈ ឆ្នាំ២០២៥**

សូមគោរព

- **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- **ឯកឧត្តមសាស្ត្រាចារ្យរង លូ លីឃាង** នាយកមន្ទីរពេទ្យព្រះអង្គឌួង
- ឯកឧត្តម លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី។

សួស្តី និងសូមស្វាគមន៍មកកាន់ស្ថានទូតជប៉ុន។ ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យា ដែលនឹងត្រូវបានអនុវត្តក្រោមជំនួយឥតសំណងគូសាណូណិសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ នាថ្ងៃនេះ។

ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបាននិងកំពុងផ្តល់ជំនួយឥតសំណងគូសាណូណិនៅកម្ពុជា ដើម្បីជួយដោយផ្ទាល់ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលកំពុងអនុវត្តគម្រោងនានា។ គូសាណូណិ មានន័យថា "ឫសស្មៅ" ក្នុងភាសាជប៉ុន។ ក្នុងរយៈពេលជាង ៣០ឆ្នាំកន្លងមកនេះ ស្ថានទូតជប៉ុន បានចូលរួមចំណែកជិត ៧០០គម្រោង នៅទូទាំងប្រទេសកម្ពុជា តាមរយៈគ្រោងការណ៍ជំនួយឥតសំណងគូសាណូណិ។ យើងមានសេចក្តីសោមនស្សរីករាយដែលគម្រោងទាំងនេះ បានចូលរួមចំណែកដោយផ្ទាល់ក្នុងការលើកកម្ពស់គុណភាពនៃជីវភាពរបស់ប្រជាជនកម្ពុជានៅកម្រិតមូលដ្ឋាន។

ពេលនេះ ខ្ញុំសូមណែនាំសង្ខេបនូវគម្រោង ដែលយើងទើបបានចុះហត្ថលេខានាថ្ងៃនេះ។

សម្រាប់គម្រោងទី១ ដែលនឹងត្រូវបានអនុវត្តដោយរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ៨៣,៦៧២ ដុល្លារអាមេរិក (ប៉ែតសិបបីពាន់ប្រាំមួយរយចិតសិបពីរដុល្លារអាមេរិក) ដើម្បីប្រើប្រាស់ឡើងវិញនូវរថយន្តបាញ់ខ្យល់ ដែលនាំចូលពីប្រទេសជប៉ុន។ យើងរំពឹងថា រថយន្តបាញ់ខ្យល់ដែលបំពាក់ដោយកង្ហារធំ និងឧបករណ៍បាញ់ខ្យល់ នឹងជួយការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាជនប្រមាណ ២,៨លាននាក់ ក្នុងរាជធានីភ្នំពេញ ដោយការបាញ់ខ្យល់ចេញយ៉ាងសកម្មពីអគារដែលមានអគ្គិភ័យ។ រថយន្តនេះដើមឡើយត្រូវបានប្រើប្រាស់ដោយទីភ្នាក់ងារគ្រប់គ្រងអគ្គិភ័យ និងគ្រោះមហន្តរាយ នៃក្រសួងកិច្ចការផ្ទៃក្នុង និងទូរគមនាគមន៍ជប៉ុន។

សម្រាប់គម្រោងទី២ ដែលនឹងត្រូវបានអនុវត្តដោយរដ្ឋបាលរាជធានីភ្នំពេញដែរនោះ រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១៥៤,៣៧៦ ដុល្លារអាមេរិក (មួយរយហាសិបបួនពាន់បីរយចិតសិបប្រាំមួយដុល្លារអាមេរិក) ដើម្បីប្រើប្រាស់ឡើងវិញនូវរថយន្តសង្គ្រោះអគ្គិភ័យចំនួនមួយ និងរថយន្តពន្លត់អគ្គិភ័យជណ្តើរយន្តចំនួនមួយដែលបានប្រើប្រាស់នៅប្រទេសជប៉ុន។ យើងរំពឹងថា រថ

យន្តទាំង២គ្រឿងនេះ នឹងជួយឱ្យក្រុមពន្លត់អគ្គិភ័យដោះស្រាយបញ្ហាអគ្គិភ័យ និងធ្វើការជួយសង្គ្រោះក្នុងករណីមានអគ្គិភ័យនៅក្នុងអគារកម្ពស់១១ជាន់ ឬស្ថានភាពលំបាកផ្សេងៗទៀតបាន។ រថយន្តទាំងនេះ នឹងបង្កើនសមត្ថភាពបច្ចេកទេសរបស់កងកម្លាំងនគរបាលពន្លត់អគ្គិភ័យរាជធានីភ្នំពេញ។

សម្រាប់គម្រោងទី៣ ដែលនឹងត្រូវបានអនុវត្តដោយមន្ទីរពេទ្យព្រះអង្គឌួង រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ២២៣,៩៥៥ ដុល្លារអាមេរិក (ពីររយម្ភៃបីពាន់ប្រាំបួនរយហាសិបប្រាំដុល្លារអាមេរិក) ដើម្បីបំពាក់បរិក្ខារវះកាត់នៅមន្ទីរពេទ្យព្រះអង្គឌួង។ យើងរំពឹងថា បរិក្ខារថ្មីនេះនឹងរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការវះកាត់ផ្នែកត្រចៀក ច្រមុះ បំពងក នៅមន្ទីរពេទ្យនេះ ដែលធ្វើរោគវិនិច្ឆ័យអ្នកជំងឺប្រមាណ ១៤,០០០នាក់ ជារៀងរាល់ឆ្នាំ។

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានសង្កេតឃើញការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជានាពេលថ្មីៗនេះ។ ទោះជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមជាច្រើន ដែល ដែលត្រូវដោះស្រាយ ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន។ ជប៉ុននឹងបន្តចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ តាមរយៈគ្រោងការណ៍ជំនួយអភិវឌ្ឍន៍ផ្លូវការផ្សេងៗ រួមទាំង "គូសាណូណិ" ផងដែរ។

ជាចុងក្រោយ ខ្ញុំសូមជូនពរ ឯកឧត្តម លោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និងសូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណសម្រាប់ការយកចិត្តទុកដាក់ស្តាប់។